HELP ME GROW

MAINE

Department of Health and Human Services

'09

ក្រុមប្រឹក្សាពិការភាពសតិបញ្ញាកុមារប្រចាំរដ្ឋមេន (Maine Developmental Disabilities Council)

Maine Developmental Disabilities Council បានចាប់ផ្តើមធ្វើការសាកល្បង ចំពោះការពិនិត្យមើលពិការភាពសតិប្រាជ្ញា នៅតាមទីតាំងចំនួនប្រាំផ្សេងគ្នា

'12

គម្រោងសមាហរណកម្មប្រព័ន្ធសង្គ្រោះពិការភាពសតិប្រាជ្ញា (Developmental Systems Integration Project (DSI))

Developmental Systems Integration បានចាប់ផ្តើមនៅឯ Quality Care ដែលបានទទួលថវិកាឧបត្ថម្ភពីមជ្ឈមណ្ឌលប្រចាំរដ្ឋមេនផ្នែកសេវាគ្រប់គ្រង និងបង្ការជំងឺ (Maine Center for Disease Control and Preventative Services Block Grant) និងថវិកាផ្នែកសុខភាពទារកមាតា (Maternal Child Health Block Grant) - បង្ករឲ្យផ្នែកសេវាថែទាំសុខភាពសាធារណៈ, ការថែទាំកុមារនៅតូច/ការថែទាំកុមារ, ការជួបគ្រួសារនៅតាមផ្ទះរបស់រដ្ឋមេន, សេវាការអភិវឌ្ឍន៍កុមារតូច, អ្នកផ្តល់សេវាថែទាំបឋម, សហព័ន្ធឪពុកម្តាយរដ្ឋមេន, សមាគមន៍អូទិសឹមរដ្ឋមេន, សម្ព័ន្ធកុមាររដ្ឋមេន និងអង្គការដទៃឲ្យធ្វើការរួមគ្នា!

'15

សន្និសិទ្ធិតំបន់ខាងកើតឆៀងខាងជើង

Maine Developmental Disabilities Council ចូលរួមសន្និបាត និងចាប់ផ្តើមរកមើលម៉ូដែលសម្រាប់ជួយកុមារលូតលាស់ (Help Me Grow System Model)

'19

ទីស្តីការកុមាររដ្ឋមេន (Maine Children's Cabinet)

ទីស្តីការកុមាររដ្ឋមេន បានចាប់ផ្តើមឡើងវិញក្នុងឆ្នាំ 2019 ៖ ការបន្តជំនួយអភិវឌ្ឍន៍មត្តេយ្យសិក្សា ការសរសេរ LD 1635 ផែនការយុទ្ធសាស្ត្រថវិកាអភិវឌ្ឍន៍មត្តេយ្យសិក្សា បានធ្វើរួចរាល់ អង្គភាព MaineCare បានចាប់ផ្តើមធ្វើផែនការសម្រាប់កម្រងសំណួរអាយុ និងដំណាក់កាល តាមអនឡាញ ដើម្បីជ្រោមជ្រែងគោលបំណងការពិនិត្យកុមារតូចតាមពេលកំណត់ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល ។

'21

L.D. 1712

អភិបាលរដ្ឋ J.Mills បានចុះហត្ថលេខាឲ្យក្លាយជាច្បាប់ L.D. 1712: ជាច្បាប់ដើម្បីជ្រោមជ្រែងការអភិវឌ្ឍន៍សុខភាពកុមារ និងភាពជោគជ័យរបស់សាលា

'22

ការអនុវត្តគម្រោង

មករា-មីនា ឆ្នាំ 2022 ក្រុមមួយត្រូវបានបង្កើតឡើង ដើម្បីអនុវត្តសកម្មភាព Help Me Grow

'22

ក្រុមរណប Help Me Grow

នៅរដូវផ្ការីក ឆ្នាំ 2022 រដ្ឋមេន បានក្លាយជាក្រុមរណបជាមួយនឹង មជ្ឈមណ្ឌលជាតិ Help Me Grow

'22

Ages & Stages Questionnaire

នៅដើមរដូវក្តៅឆ្នាំ 2022 រដ្ឋមេនបានបង្កើតឲ្យមាននូវកម្មវិធី Ages & Stages Questionnaire សាកល្បង ដោយមានផ្តល់សេវាចំនួន 18 ប្រភេទ

'22

ការបើកដំណើរការកម្មវិធី HMG Maine

រដូវក្តៅឆ្នាំ 2022 រដ្ឋមេនបានចាប់ផ្តើមដាក់ឲ្យដំណើរការកម្មវិធី Help Me Grow និងជួយកុមារចាប់ពីនៅក្នុងផ្ទៃ រហូតដល់អាយុ 8 ឆ្នាំ ។